ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ ០០១ សហវ.ថហ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០០២

# សារាចរ

# ស្តីពីការណែនាំអនុវត្តថវិការដ្ឋឆ្នាំ ២០០២

## I. សេចក្តីផ្តើម

១. ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០១/១៥ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ។

ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណូលថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ និង អនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ និង អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា ។

ផ្អែកលើមូលដ្ឋាននៃអនុក្រឹត្យខាងលើនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចេញប្រកាសលេខ ០០១ សហវ.ថហ.ប្រក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាទូទៅរបស់រដ្ឋ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ និង ប្រកាសលេខ ០០២ សហវ.ថហ.ប្រក ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូក តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

ដើម្បីឱ្យការអនុវត្តន៍ច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២នេះ ដំណើរការទៅប្រកបដោយលទ្ធផលល្អ និង មានប្រសិទ្ធិភាពខ្ពង់ខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សូមធ្វើការណែនាំអនុវត្តថវិការដ្ឋឆ្នាំ ២០០២ មានដូចខាងក្រោមនេះ ៖

២. ជាបឋមចាំបាច់ត្រូវរំលឹកថា ថវិការដ្ឋឆ្នាំ ២០០២នេះ ត្រូវបានរៀបចំឡើងដល់ទៅពីរដង ។ ពេលព្រាងលើកទី ១ គឺឈរលើសម្មតិកម្ម Hypothèse នៃសភាពការណ៍សេដ្ឋកិច្ចក្នុងប្រទេស និង អន្តរជាតិ មុនព្រឹត្តិការណ៍ដ៏រន្ធត់ថ្ងៃទី ១១ ខែ កញ្ញា ។ ពេលកំពុងរៀបចំបញ្ចប់សេចក្តីព្រាងច្បាប់លើកទី ១ នោះ ក្រសួង

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបង្ខំចិត្តសើរើ Hypothèse ឡើងវិញមុនដាក់ជូនគណៈរដ្ឋមន្ត្រី ក្រោយពីឃើញទំហំនៃបច្ច័យអាក្រក់ បន្ថែមលើឱនភាពសេដ្ឋកិច្ចសកលលោក ។ តាមការប៉ាន់ប្រមាណរបស់សេដ្ឋកិច្ចវិទូនានាថា សេដ្ឋកិច្ចសកលលោក នឹងមិនងើបឡើងវិញ មុនដំណាច់ត្រីមាសទី ២ ឆ្នាំ ២០០២ទេ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ថវិកាជាតិឆ្នាំ ២០០២ ជាថវិកាដែលមានបង្ហាញនូវឆន្ទៈនយោបាយមោះមុត ក្នុងការបន្តអនុវត្តនូវកម្មវិធីនយោបាយ និង កម្មវិធីកំណែទម្រង់លើគ្រប់ផ្នែករបស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទីពីរនេះ ។ ថវិកាជាតិឆ្នាំ ២០០២នេះ មានជាគោលសំខាន់ៗ ដូចតទៅ ÷

ក) ដោយឈរលើមូលដ្ឋាន នៃការវិវត្តន៍ស្ថានភាពនយោបាយ និង យុទ្ធសាស្ត្រថវិកាជាតិឆ្នាំ ២០០២ ឆ្លុះបញ្ចាំងនូវសភាពការណ៍សំខាន់ៗ ដូចតទៅ ÷

ទី១- ការបន្តអនុវត្ត នូវយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ។

ទី២- ការបន្តអនុវត្ត នូវផែនការសកម្មភាពអភិបាលកិច្ច ។

ទី៣- ការបន្តអនុវត្ត នូវផែនការអភិវឌ្ឍន៍ ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង រចនាសម្ព័ន្ធសង្គម ។

ទី៤- ឆ្នាំ ២០០២ ជាឆ្នាំដ៏សំខាន់នៃការបន្តកំណែទម្រង់ស៊ីជម្រៅ របស់រាជរដ្ឋាភិបាល ពិសេសកម្មវិធីវិមជ្ឈការ ក្នុងនោះ មានចំណាយសំរាប់រៀបចំការបោះឆ្នោតឃុំ-សង្កាត់ ជាដើម ។

ខ) ថវិកាជាតិឆ្នាំ ២០០២ គឺជាឧបករណ៍ដើម្បីធានាឱ្យបាន នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ដែលជាគន្លឹះក្នុងការសំរេចឱ្យបាន នូវសមិទ្ធិផលសេដ្ឋកិច្ច និង សង្គមកិច្ចសំខាន់ៗ ។ ថវិកាជាតិឆ្នាំ ២០០២ នឹងពង្រឹងចលនាការនៃកំណើន ដើម្បីសំរេចបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច ប្រកបដោយចីរភាព ។

គ) ពង្រឹងការកៀងគរធនធានហិរញ្ញវត្ថុបន្ថែមទៀត ទាំងចំណូលសារពើពន្ធ និង ចំណូលពុំមែនសារពើពន្ធ ដើម្បីសំរេចឱ្យបាននូវការប្រមូលចំណូលក្នុងស្រុក ចំនួន **១៣%នៃផសស** តាមការគ្រោងទុក ។ រាជរដ្ឋាភិបាល នឹងបន្តធ្វើវិចារណកម្មលើអាទិភាពចំណាយ ដោយផ្តោតជាសំខាន់លើការបង្កើនចំណាយសំរាប់អភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច និង សង្គមកិច្ច ជាពិសេសវិស័យអប់រំ សុខាភិបាល កសិកម្ម និង អភិវឌ្ឍន៍ជនបទ ដើម្បីសំរេចឱ្យបាននូវ គោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធនឹងភាពក្រីក្រ ។

ឃ) ពង្រឹង និង ពន្លឿនការអនុវត្តន៍នូវកម្មវិធីកាត់រំសាយកងទ័ព ក្នុងគោលដៅដែលជាការចាប់ផ្តើមការបង្វែរ ពីចំណាយការពារប្រទេស ទៅចំណាយសំរាប់ការអភិវឌ្ឍន៍វិស័យសង្គមកិច្ច និង សេដ្ឋកិច្ច ។ ដើម្បីសំរេចបាននូវទិសដៅនេះ រាជរដ្ឋាភិបាល នឹងអនុវត្តឱ្យបានស៊ីជម្រៅនូវកំណែទម្រង់រចនាសម្ព័ន្ធ ដោយកាត់បន្ថយកងទ័ពក្នុងកងយោធពលខេមរៈភូមិន្ទ និង ធ្វើកំណែទម្រង់កងទ័ព ដើម្បីអនុវត្តនូវឯកសារ **"សៀវភៅសការពារជាតិ"** ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងចូលរួមចំណែក តាមរយៈការផ្តល់ប្រាក់ឧបត្ថម្ភ សំរាប់យោធិន ដែលត្រូវកាត់រំសាយ ។

– ក្នុងរយៈពេលចាប់ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២៥ នៃខែចុងត្រីមាសមុន នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច ត្រូវប្រជុំពិភាក្សាជាមួយនាយកដ្ឋានពន្ធដារ ទីចាត់ការគយ និង រដ្ឋាករ ធនាគារជាតិ និង នាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំកម្មវិធីចំណូល ចំណាយថវិការដ្ឋ សំរាប់ត្រីមាសបន្ទាប់ ។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល ចំណាយនេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ធ្វើប្រកាសប្រគល់កម្មវិធីចំណូល ចំណាយសំរាប់ត្រីមាសបន្ទាប់ តាមជំពូកថវិកា ក្នុងកំរិតឥណទានអតិបរិមា ជូនដល់ក្រសួងស្ថាប័ននិមួយៗ និង មន្ទីរជំនាញខេត្ត-ក្រុងនិមួយៗ ដោយចម្លងជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រតនាគារ និង អភិបាលខេត្ត-ក្រុង ។

– ក្រសួងស្ថាប័ន និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខេត្ត-ក្រុង ត្រូវធ្វើរបាយការណ៍ចំណូល ចំណាយ ប្រចាំខែ ប្រចាំត្រីមាស រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ដូចមានចែងក្នុងមាត្រា ១៣ ច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

– អាណាប័កដើមខ្សែ ឬ អាណាប័កតាមការប្រទានសិទ្ធ ត្រូវចេញអាណត្តិបើកប្រាក់ នៅក្នុងវង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និង រតនាគារ ត្រូវចុះទិដ្ឋាការលើ អាណត្តិបើកប្រាក់ និង ត្រូវបើកផ្ដល់សាច់ប្រាក់ តែនៅក្នុងកំរិតនៃកម្មវិធីប្រចាំត្រីមាសនេះ តែប៉ុណ្ណោះ ។ ក្នុងករណីមានការចាំបាច់ សុំបើកផ្ដល់បន្ថែម ត្រូវធ្វើឡើងតាមប្រកាសផ្ដល់កម្មវិធីបន្ថែម របស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅក្នុងក្របខ័ណ្ឌឥណទានថវិកា ដែលមិនទាន់បែងចែកទៅក្នុងកម្មវិធីចំណាយ ។

– រតនាគារត្រូវបញ្ជូនមក នាយកដ្ឋានថវិកានីយកម្ម និង ហិរញ្ញកិច្ច នូវរបាយការណ៍បេឡាប្រចាំថ្ងៃ របាយការណ៍ចំណូល ចំណាយថវិកាប្រចាំខែ ព្រមទាំងសាលាកបត្របង់ប្រាក់ និង តារាងតុល្យភាពប្រចាំខែ ដើម្បីតាមដានបូកសរុបចំណូល ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតំលៃនូវ សភាពការណ៍អនុវត្ត ប្រៀបធៀបនឹងខែមុន ត្រីមាសមុន នៃឆ្នាំនេះ និង ប្រៀបធៀបនឹងខែ ត្រីមាសដូចគ្នា នៃឆ្នាំមុន ។

## VII. នីតិវិធីចលនាឥណទានថវិកា

១៨. ក្រសួងស្ថាប័ន និង មន្ទីរជំនាញខេត្ត-ក្រុង ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួន ទៅតាមប្រកាស របស់ក្រសួសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដូចមានលំអិតនៅក្នុងសៀវភៅថវិកា ។ ក្នុងករណីដែលមានខ្ទង់ថវិកាណា មួយមិនគ្រប់ តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាព មកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ពិនិត្យសំរេច ។ បើក្រសួងស្ថាប័ន មានសំណូមពរផ្ដល់ឥណទានបន្ថែម ដូចជាចំណាយ ដំណើរការរដ្ឋបាល សំភារៈ ការជួសជុលតូច ការសាងសង់ និង ទិញសំភារៈ ។ល។ ទៅឱ្យមន្ទីរជំនាញរបស់ខ្លួន នៅខេត្ត-ក្រុង នោះគឺ ត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទាន របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលខេត្ត-ក្រុង (អាណាប័កតាមការប្រទានសិទ្ធ) ដែលជាខ្សែទទឹង និង មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អាចតាមដានការ

ប្រើប្រាស់ឥណទានថវិកា បន្ថែមទាំងនោះបាន ។ ចំពោះការស្នើសុំនិយ័តភាពឥណទានថវិកា នៅផ្ទៃក្នុង ក្រសួងស្ថាប័ន និង មន្ទីរជំនាញខេត្ត ក្រុង នៅក្នុងត្រីមាសទី ១ ឆ្នាំ ២០០២នេះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនពិនិត្យសំរេចអនុញ្ញាតជូនទេ ។

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មានសេចក្តីសង្ឃឹមលើការយកចិត្តទុកដាក់ របស់ក្រសួងស្ថាប័ន និង ខេត្ត-ក្រុង ក្នុងការអនុវត្តន៍ថវិកាឆ្នាំ ២០០២ ប្រកបដោយលទ្ធផលល្អប្រសើរ ទៅតាមកម្មវិធីនយោបាយ របស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូន</u>

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- ខុទ្ទកាល័យ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
  (ដើម្បីជ្រាបជាពត៌មាន)
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់ខេត្ត ក្រុង
  (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ